ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ក្របខ័ណ្ឌថវិការយៈពេលមធ្យម
# ឆ្នាំ ២០២៦-២០២៨

ខែ ឧសភា ឆ្នាំ ២០២៥

# មាតិកា

**១. សេចក្តីផ្តើម** ........................................ ១

**២. ក្របខណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** ........................................ ១

**២.១. ក្របខណ្ឌចំណូល** ........................................ ២

**២.២. ក្របខណ្ឌចំណាយ** ........................................ ៤

២.២.១. ក្របខណ្ឌចំណាយថ្នាក់ជាតិ ........................................ ៥

២.២.២. ក្របខណ្ឌចំណាយថ្នាក់ក្រោមជាតិ ........................................ ៨

**៣. សេចក្តីសន្និដ្ឋាន** ........................................ ៩

**ឧបសម្ព័ន្ធស្តីពីពិតានចំណាយគោលឆ្នាំ ២០២៦-២០២៨ សម្រាប់ក្រសួង ស្ថាប័ន និង សម្រាប់ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល** ........................................ ១០

## ១. សេចក្តីផ្តើម

អនុលោមតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ចេញនូវសារាចរស្តីពីប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ កាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៥ ដែលក្នុងនោះបានកំណត់អំពីពេលនៃការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ដែលត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី នៅមុនដំណាច់ខែ មេសា សម្រាប់ជាមូលដ្ឋាននៃការរៀបចំក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ដែលត្រូវអនុម័តដោយប្រមុខរាជរដ្ឋាភិបាលនៅក្នុងខែ ឧសភា ព្រមជាមួយនឹងការដាក់ចេញនូវសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦។ ជាក់ស្តែង, ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខ័ណ្ឌថវិការយៈពេលមធ្យម គឺជាផែនការរយៈពេលមធ្យមកម្រិតយុទ្ធសាស្ត្រ ដែលត្រូវបានរៀបចំតាមអភិក្រមពីលើចុះក្រោម (Top Down) មានភាពប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមករវាងក្របខ័ណ្ឌទាំងពីរនេះ ដែលផ្តល់ជាទស្សនវិស័យ និងតម្រង់ទិសការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការគ្រប់គ្រងថវិកាជាតិទាំងផ្នែកចំណូល និងផ្នែកចំណាយ សម្រាប់រយៈពេលមធ្យម។

ផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ដែលទទួលបានការអនុម័តរបស់គណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២៥, **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** ឬហៅខ្លីថា **«ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៦-២០២៨»** ត្រូវបានរៀបចំជាឯកសារមួយបន្ថែមទៀតជាពិសេស ដើម្បីលម្អិតក្របខ័ណ្ឌចំណាយថវិការយៈពេលមធ្យមពីកម្រិតវិស័យ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ទៅដល់កម្រិតក្រសួង ស្ថាប័ន ដើម្បីផ្តល់ជាទស្សនវិស័យអំពីលទ្ធភាពថវិការយៈពេលមធ្យម ទាំង**ផ្នែកចំណាយចរន្ត** និង**ផ្នែកចំណាយមូលធន** តាមរយៈការកំណត់ និងដាក់ចេញនូវពិតានចំណាយគោលសម្រាប់រយៈពេល ៣ ឆ្នាំ ជូនដល់ក្រសួង ស្ថាប័ន ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់អនុវត្តការប្រគល់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលពិតានចំណាយគោលនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការដាក់ចេញនូវសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ២០២៦ ដើម្បីគ្រប់ក្រសួង ស្ថាប័ន មានមូលដ្ឋានច្បាស់លាស់ក្នុងការលើកគម្រោងថវិកា។ លើសពីនេះ, **ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៦-២០២៨** ក៏មានសារៈសំខាន់យ៉ាងខ្លាំងជួយដល់ក្រសួង ស្ថាប័ន ក្នុងការពង្រឹងការធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន ទាំងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស និងទាំងចំណាយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។

## ២. ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨

ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងលក្ខខណ្ឌជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៥ និងការព្យាករសម្រាប់ឆ្នាំ ២០២៦-២០២៨, **ជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល** សម្រាប់រយៈពេលខ្លី និង មធ្យម ខាងមុខ ត្រូវបានរៀបចំឡើង ដោយបន្តប្រកាន់យកការអនុវត្ត **«ជំហរគោលនយោបាយពង្រឹងប្រសិទ្ធភាពថវិកាជាជំហាន (Gradual Fiscal Consolidation Stance)»** ដើម្បីធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលមធ្យម តាមរយៈការបន្តរក្សានូវតុល្យភាពថវិការវាងធនធានថវិការបស់រដ្ឋ និងបន្ទុកថវិការបស់រដ្ឋ និងចាប់ផ្តើមកសាងទ្រនាប់ថវិកាជាតិឡើងវិញ នៅពេលកាលៈទេសៈអនុញ្ញាត។

លើមូលដ្ឋាននៃជំហរគោលនយោបាយហិរញ្ញវត្ថុសាធារណៈនេះ **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** ត្រូវបានដាក់ចេញក្នុងក្របខ័ណ្ឌតុល្យភាព ដូចខាងក្រោម៖

**តារាងទី ១ : ក្របខ័ណ្ឌតុល្យភាពថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨**

| ភាគរយនៃ ផ.ស.ស. | 2025ច្បា. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|
| **ចំណូលសរុបថវិការដ្ឋ** | **15,31%** | **14,63%** | **14,48%** | **14,43%** |
| ចំណូលចរន្តថវិការដ្ឋ | 14,72% | 14,13% | 14,01% | 13,98% |
| **ចំណាយសរុបថវិការដ្ឋ** | **18,39%** | **16,83%** | **16,57%** | **16,74%** |
| ចំណាយចរន្តថវិការដ្ឋ | 12,62% | 12,05% | 11,84% | 11,47% |
| ចំណាយមូលធនថវិការដ្ឋ | 5,76% | 4,78% | 4,73% | 5,27% |
| **អតិរេកចរន្ត** | **2,10%** | **2,08%** | **2,16%** | **2,51%** |
| **សមតុល្យថវិកា** | **-3,08%** | **-2,19%** | **-2,09%** | **-2,32%** |
| ***តម្រូវការហិរញ្ញប្បទាន*** | ***4,25%*** | ***3,60%*** | ***3,76%*** | ***3,88%*** |
| *ឱនភាពថវិកា* | 3,08% | 2,19% | 2,09% | 2,32% |
| *ការទូទាត់ការខ្ចី* | 1,18% | 1,20% | 1,25% | 1,14% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0,00% | 0,20% | 0,42% | 0,42% |
| ***ប្រភពហិរញ្ញប្បទាន*** | ***4,25%*** | ***3,60%*** | ***3,76%*** | ***3,88%*** |
| *ហិរញ្ញប្បទានក្រៅប្រទេស* | 3,06% | 2,95% | 2,83% | 3,04% |
| *មូលនិធិទ្រទ្រង់ថវិកា* | 0,96% | 0,22% | 0,24% | 0,16% |
| *ការបោះផ្សាយមូលបត្ររដ្ឋ* | 0,24% | 0,23% | 0,28% | 0,26% |
| *ប្រាក់បញ្ញើរាជរដ្ឋាភិបាល* | 0,00% | 0,00% | 0,00% | 0,00% |
| *ការបង្វិលសងអាករលើតម្លៃបន្ថែម* | 0,00% | 0,20% | 0,42% | 0,42% |

ជារួម, **ក្របខ័ណ្ឌចំណាយសម្រាប់ឆ្នាំ ២០២៦-២០២៨** ត្រូវបានគ្រោងឡើងស្របតាមជំហរគោលនយោបាយដែលបានដាក់ចេញ ដែលឱនភាពថវិកាក្នុងរយៈពេលមធ្យម នឹងមានការរួមតូច ធៀបនឹងឆ្នាំ ២០២៥ ដោយរាជរដ្ឋាភិបាលគ្រោងមិនដកប្រាក់សន្សំមកប្រើប្រាស់, លើកលែងតែក្នុងករណីចាំបាច់បំផុត។

## ២.១. ក្របខ័ណ្ឌចំណូល

**តាមក្របខ័ណ្ឌតុល្យភាពរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ខាងលើ ចំណូលសរុបថវិការដ្ឋក្នុងឆ្នាំ ២០២៦ ត្រូវបានព្យាករថានឹងសម្រេចបានក្នុងទំហំប្រមាណ ១៤,៦៣% នៃ ផ.ស.ស. គឺកើនចំនួនប្រមាណ ២,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ក្នុងនោះ៖**

- **<u>ចំណូលចរន្តថវិការដ្ឋ</u> ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១៤,១៣% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥** ក្នុងនោះ៖

➢ **ចំណូលសារពើពន្ធថវិការដ្ឋ** ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១២,១៧% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ២,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ក្នុងនោះ : ប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ៥,២៤% នៃ ផ.ស.ស., និងចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ៦,៩៣% នៃ ផ.ស.ស.

➢ **ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ** ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ១,៩៥% នៃ ផ.ស.ស., គឺកើនក្នុងរង្វង់ ៩,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។

- **<u>ចំណូលផ្សេងៗ</u>** ត្រូវបានរំពឹងទុកថានឹងសម្រេចបានប្រមាណ ០,៥១% នៃ ផ.ស.ស., គឺថយក្នុងរង្វង់ ៦,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។

**ចំណូលសរុបថវិការដ្ឋ ក្នុងរយៈពេលមធ្យមឆ្នាំ ២០២៧-២០២៨ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៣% និងស្ថិតក្នុងទំហំ ១៤,៤៣% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨។** ក្នុងនោះ, ចំណូលចរន្តថវិការដ្ឋ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យម ក្នុងអត្រា ៧,៥% និងស្ថិតក្នុងរង្វង់ ១៣,៩៨% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨ ដែលក្នុងនោះ ចំណូលប្រមូលដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានរំពឹងថានឹងសម្រេចបានជាមធ្យមក្នុងអត្រា ៦,៥%, ខណៈចំណូលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានព្យាករថានឹងសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ៧,២%។ ជាមួយគ្នានេះ, ចំណូលមិនមែនសារពើពន្ធ ត្រូវបានរំពឹងថាសម្រេចបានកំណើនជាមធ្យមក្នុងអត្រា ១១,២% និងស្ថិតក្នុងរង្វង់ ២,០៧% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨ ជាមួយនឹងការបន្តពង្រឹងការកៀរគរចំណូលពីប្រភពដែលនៅមានសក្តានុពល, ស្របពេលដែលចំណូលពីសម្បទានរ៉ែ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ផលទុនសកម្មភាពទេសចរណ៍ អាករស្ថានទូត និងផលទុនរបស់អាកាសចរស៊ីវិល ត្រូវបានរំពឹងទុកថានឹងបន្តរើបឡើង។

ដើម្បីសម្រេចឱ្យបាននូវលទ្ធផលតាមការព្យាករណ៍ខាងលើ និងឆ្លើយតបនឹងបញ្ហាប្រឈមលើការប្រមូលចំណូល ព្រមទាំងទ្រទ្រង់ចលនការនៃចីរភាពកំណើនសេដ្ឋកិច្ច ស្របតាមក្របខ័ណ្ឌចំណូលរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ខាងលើ, រាជរដ្ឋាភិបាលនឹងបន្តពង្រឹកមូលដ្ឋានចំណូលប្រកបដោយភាពហ្មត់ចត់ ជាពិសេសអនុវត្តវិធានការគន្លឹះផ្នែកចំណូល ដូចមានចែងលម្អិត នៅក្នុងឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ២០២៦-២០២៨។

**តារាងទី ២ : ក្របខ័ណ្ឌចំណូលរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨**

| ភាគរយនៃ ផ.ស.ស. | 2025ច្ប. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|
| **ចំណូលសរុបថវិការដ្ឋ** | **15,31%** | **14,63%** | **14,48%** | **14,43%** |
| **ចំណូលចរន្តថវិការដ្ឋ** | **14,72%** | **14,13%** | **14,01%** | **13,98%** |
| **ចំណូលសារពើពន្ធថវិការដ្ឋ** | **12,80%** | **12,17%** | **12,00%** | **11,91%** |
| អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | 4,92% | 5,24% | 5,15% | 5,09% |
| អគ្គនាយកដ្ឋានពន្ធដារ | 7,88% | 6,93% | 6,85% | 6,82% |
| *ក្នុងនោះ: ថ្នាក់ក្រោមជាតិ* | *1,07%* | *0,90%* | *0,89%* | *0,89%* |
| **ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ** | **1,92%** | **1,95%** | **2,01%** | **2,07%** |
| *ក្នុងនោះ: ថ្នាក់ក្រោមជាតិ* | *0,15%* | *0,14%* | *0,13%* | *0,13%* |
| **ចំណូលផ្សេងៗ** | **0,59%** | **0,51%** | **0,48%** | **0,45%** |

## ២.២. ក្របខ័ណ្ឌចំណាយ

**ក្របខ័ណ្ឌចំណាយសម្រាប់ឆ្នាំ ២០២៦-២០២៨** ត្រូវបានគ្រោងឡើងស្របតាមជំហរគោលនយោបាយដែលបានដាក់ចេញ ដោយរៀបចំលើមូលដ្ឋានតុល្យភាពនៃចំណូលនិងចំណាយ និងពុំមានការប្រើប្រាស់ប្រាក់សន្សំរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ, ការគ្រោងចំណាយសាធារណៈសម្រាប់រយៈពេលមធ្យម ត្រូវបានរៀបចំប្រកបដោយភាពប្រុងប្រយ័ត្ន និងបុរេសកម្មខ្ពស់ ដោយឈរលើគោលការណ៍គោរពមឹងម៉ាត់វិន័យថវិកា និងពង្រឹងប្រសិទ្ធភាពថវិកា តាមរយៈការបន្តខិតខំកែលម្អការវិភាជថវិកាឱ្យកាន់តែចំទិសដៅ និងចំតម្រូវការចាំបាច់ជាក់ស្តែងទៅកាន់មុខសញ្ញាដែលជាអាទិភាពសំខាន់ៗចំពោះមុខ និងស្របតាមទិសដៅជាយុទ្ធសាស្ត្រ ដែលត្រូវបានដាក់ចេញក្នុង **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា។

យ៉ាងណាមិញ, ការដាក់ចេញនូវវិធានការគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក បាននាំមកនូវភាពមិនប្រាកដប្រជាកាន់តែខ្ពស់, ពិបាកប៉ាន់ស្មាន និងបង្កឱ្យមានកម្មវិបាកជាអវិជ្ជមាន មកលើទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា, ទាំងក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។ ដូចនេះ, ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ជាពិសេស ក្របខ័ណ្ឌចំណាយឆ្នាំ ២០២៦ បានគិតគូរធ្វើអាទិភាពូបនីយកម្មចំណាយ ដោយផ្តោតជាចម្បងលើការរក្សាលំនឹងសង្គម-សេដ្ឋកិច្ច, ការបន្តអនុវត្តគោលនយោបាយគាំពារសង្គម, ការអភិវឌ្ឍមូលធនមនុស្ស, ការពង្រឹងសមត្ថភាពស្ថាប័ន, ការកែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ជារចនាសម្ព័ន្ធ ព្រមទាំងការអនុវត្តគោលនយោបាយអាទិភាពគន្លឹះ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង, បង្កើនផលិតភាព និងជំរុញការធ្វើពិពិធកម្មឱ្យខ្លាំងក្លា សំដៅកសាងមូលដ្ឋានគ្រឹះ ដ៏រឹងមាំសម្រាប់កំណើន និងការបង្កើតការងារ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ និងមានភាពធន់សម្រាប់កិច្ចអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច គាំទ្រដល់ការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច។

**ផ្អែកលើក្របខ័ណ្ឌតុល្យភាពថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨ ដែលត្រូវបានដាក់ចេញដោយក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨, ចំណាយសរុបថវិការដ្ឋឆ្នាំ ២០២៦ ត្រូវបានគ្រោងក្នុងទំហំ ១៦,៨៣% នៃ ផ.ស.ស. គឺថយប្រមាណ ១,៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។ សម្រាប់ឆ្នាំ ២០២៧-២០២៨, កញ្ចប់ចំណាយសរុប នឹងគ្រោងឱ្យមានកំណើនសមគួរឡើងវិញ ក្នុងអត្រាជាមធ្យមប្រមាណ ៧,៨% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៦,៧៤% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨។**

- **ចំណាយចរន្តថវិការដ្ឋ** ត្រូវបានគ្រោងក្នុងទំហំ ១២,០៥% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៦ ដែលមានកំណើនប្រមាណ ២,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។ សម្រាប់ឆ្នាំ ២០២៧-២០២៨, ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងឱ្យមានកំណើន ក្នុងអត្រាជាមធ្យមប្រមាណ ៥,៥% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១១,៤៧% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨។ **ចំណាយបន្ទុកបុគ្គលិក ក្នុងឆ្នាំ ២០២៦** ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា **២,៤%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ សម្រាប់ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ និងការត្រៀមថវិកាសម្រាប់ចំណាយលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ក្នុងរដ្ឋបាលសាធារណៈ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព។ **សម្រាប់ឆ្នាំ ២០២៧-២០២៨,** ចំណាយបន្ទុកបុគ្គលិកត្រូវបានគ្រោងកើនជាមធ្យមក្នុងអត្រា ៤,២%។ ចំពោះ, **ចំណាយមិនមែនបន្ទុកបុគ្គលិក** ក្នុងឆ្នាំ ២០២៦ ត្រូវបានគ្រោងឱ្យមានកំណើនក្នុងអត្រា **២,៦%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥ ស្របតាមស្មារតី

នៃការពង្រឹងប្រសិទ្ធភាពវិភាជថវិកា តាមរយៈការខិតខំតម្រង់ការវិភាជថវិកាឱ្យបានត្រឹមត្រូវ និងចំគោលដៅជាពិសេស សម្រាប់ឆ្លើយតបទៅនឹងកំណើននៃតម្រូវការចំណាយក្នុងការអនុវត្តគោលនយោបាយគាំពារសង្គម, ការត្រៀមលក្ខណៈក្នុងការអន្តរាគមន៍ក្បោលនឹងសង្គម-សេដ្ឋកិច្ច និងចំណាយកាតព្វកិច្ច ក៏ដូចជាចំណាយចាំបាច់មិនអាចពន្យារពេលបាន។ ទន្ទឹមនេះ, ខិតខំធ្វើវិចារណកម្មចំណាយដោយត្បិតត្បៀតលើមុខសញ្ញាចំណាយមិនចាំបាច់ និងមិនសូវចាំបាច់ ដើម្បីរក្សាឱ្យបាននូវនិរន្តរភាពប្រតិបត្តិការរបស់ក្រសួង ស្ថាប័ន, បន្តជំរុញកម្មវិធីកែទម្រង់ជាអាទិភាព ក៏ដូចជាកម្មវិធីកែទម្រង់គន្លឹះនានា។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលក៏បានត្រៀមកញ្ចប់ថវិកាក្នុងកញ្ចប់ចំណាយត្រៀមបម្រុងមានមុខសញ្ញាសម្រាប់អនុវត្តនូវកម្មវិធីអន្តរាគមន៍ ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និងលើកកម្ពស់សមធម៌សង្គមផងដែរ។ ដោយឡែក, សម្រាប់ឆ្នាំ ២០២៧-២០២៨ ត្រូវបានគ្រោងឱ្យមានកំណើនជាមធ្យមក្នុងអត្រា ៦,៥%។

- **ចំណាយមូលធនថវិការដ្ឋ ត្រូវបានគ្រោងក្នុងទំហំ ៤,៧៨% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០២៦ ដែលមានកំណើនអវិជ្ជមានក្នុងអត្រា -១០,៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥។** កំណើនអវិជ្ជមាននេះ បណ្ដាលមកពីការថមថយនូវមូលនិធិទ្រទ្រង់ថវិកា ដែលជាប្រភពហិរញ្ញប្បទានក្រៅប្រទេស និងការបាត់បង់លក្ខខណ្ឌអនុគ្រោះពីប្រភពហិរញ្ញប្បទានប្រពៃណីដែលមានទម្រង់ជាហិរញ្ញប្បទានឥតសំណង និងឥណទានមានកម្រិតសម្បទានខ្ពស់ បន្ទាប់ពីការចាកចេញពីចំណាត់ថ្នាក់ប្រទេសមានចំណូលទាប។ យ៉ាងណាមិញ, ចំណាយមូលធនក្នុងឆ្នាំ ២០២៦ នៅតែបន្តផ្តល់ការគិតគូរដល់គម្រោងវិនិយោគសាធារណៈអាទិភាព ស្របតាមគោលដៅអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងតាមលទ្ធភាពដែលអាចទ្រទ្រង់បាន **ខណៈចំណាយវិនិយោគសាធារណៈ ដោយប្រភពហិរញ្ញប្បទានក្នុងប្រទេស ត្រូវបានរក្សាក្នុងកម្រិតស្មើច្បាប់ថវិកាឆ្នាំ ២០២៥។ សម្រាប់ឆ្នាំ ២០២៧-២០២៨ ចំណាយមូលធន ត្រូវបានគ្រោងឱ្យមានកំណើនឡើងវិញ** ក្នុងអត្រាជាមធ្យមប្រមាណ ១៣,៧% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ៥,២៧% នៃ ផ.ស.ស. នៅឆ្នាំ ២០២៨។ កំណើននេះ បានគិតគូរពីតម្រូវការចំណាយចាំបាច់សម្រាប់ការអភិវឌ្ឍ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន, ការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, ការលើកកម្ពស់ភាពប្រកួតប្រជែង និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច ពោលគឺ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ទៅលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ជាពិសេស តាមរយៈការបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានគុណភាពខ្ពស់ និងការបង្កើនបរិមាណ និងគុណភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតង ដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល និងការបន្តជួសជុល, ស្ពាន និងកែលម្អហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា។

### ២.២.១. ក្របខ័ណ្ឌចំណាយថ្នាក់ជាតិ

**ចំណាយសរុបថ្នាក់ជាតិក្នុងឆ្នាំ ២០២៦ ត្រូវបានគ្រោងក្នុងទំហំ ១៥,៧៩% នៃ ផ.ស.ស. គឺថយប្រមាណ ១,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២៥។** សម្រាប់ឆ្នាំ ២០២៧-២០២៨ ចំណាយសរុបថ្នាក់ជាតិ នឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៧,៩% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១៥,៧៣% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨។

ផ្អែកលើ**ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨, ក្របខ័ណ្ឌចំណាយតាមវិស័យរយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** ត្រូវបានគិតបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនទាំងលទ្ធភាព ហិរញ្ញប្បទានដោយថវិកាជាតិ និងលទ្ធភាពហិរញ្ញប្បទានក្រៅប្រទេស ទាំងទ្វេភាគី និងពហុភាគី ហើយត្រូវបានកំណត់ដូចតទៅ៖

- **វិស័យរដ្ឋបាលទូទៅ** ត្រូវបានគ្រោងប្រមាណ ១,៥៣%, ១,៥៩%, និង ១,៥៥% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា សំដៅបន្តគាំទ្រការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការងារការទូតសេដ្ឋកិច្ច បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ការងារទាក់ទាញនិងការគ្រប់គ្រង វិនិយោគឯកជន និងការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍ ការធ្វើទំនើបកម្ម និងប្រព័ន្ធស្វ័យប្រវត្តិកម្មរដ្ឋបាលសារពើពន្ធ ការធ្វើទំនើបកម្មការគ្រប់គ្រងចំណាយសាធារណៈ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ចធុរកិច្ចនិងសង្គមឌីជីថល ព្រមទាំងការបន្តត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»**។
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** ត្រូវបានគ្រោងប្រមាណ ២,៦១%, ២,៥១%, និង ២,៤២% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា សំដៅបន្តគាំទ្រដល់ការអនុវត្តកិច្ចការពារអធិបតេយ្យជាតិ, ការអនុវត្តកិច្ចការសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ, ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ សង្កាត់មានសុវត្ថិភាព», ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យព្រំដែន, ការអភិវឌ្ឍចំណេះដឹង និងជំនាញវិជ្ជាជីវៈជូនកងកម្លាំងនគរបាលជាតិ, ការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់-អាវុធ និងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។
- **វិស័យសង្គមកិច្ច** ត្រូវបានគ្រោងប្រមាណ ៤,៩៥%, ៤,៩៦%, និង ៤,៨៩% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា **ពោលគឺនៅតែចាត់ទុកជាវិស័យអាទិភាពទី ១** ក្នុងនោះសំដៅ បន្តរក្សាលំនឹងជីវភាពប្រជាជន ព្រមទាំងលើកកម្ពស់សមធម៌សង្គម, បន្តលើកកម្ពស់គុណភាពអប់រំ និងគាំទ្រដល់ការពង្រឹង និងពង្រីកការទទួលបានសេវាអប់រំ និងការអភិវឌ្ឍជំនាញ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ លើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាពឆ្ពោះទៅរកការគ្របដណ្តប់សុខភាពសកលជំរុញការអនុវត្តកម្មវិធីគោលនយោបាយជាតិគាំពារសង្គម, ការបន្តផ្តល់របបសន្តិសុខសង្គម, ការលើកកម្ពស់យេនឌ័រ និងការបន្តគាំទ្រដល់គោលនយោបាយអាទិភាពផ្សេងទៀត ក្នុងផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន។
- **វិស័យសេដ្ឋកិច្ច** ត្រូវបានគ្រោងប្រមាណ ៣,៧១%, ៣,៥៣%, និង ៣,៧៩% នៃ ផ.ស.ស. សម្រាប់ឆ្នាំ ២០២៦, ២០២៧ និង ២០២៨ រៀងគ្នា ដោយផ្តោតសំខាន់ លើការលើកកម្ពស់ផលិតភាពស្របតាមស្តង់ដា និងតម្រូវការទីផ្សារ បន្តដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ទូទាំងប្រទេស ដើម្បីជំរុញ ការលើកកម្ពស់ផលិតភាពកសិកម្ម និងការរៀបចំឱ្យមានសមាគមកសិកម្មនៅតាមទីជនបទ គាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ការអនុវត្ត **យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធឆ្នាំ ២០២៣-២០២៨ គោល-នយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥** និង **គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០**។ល។

## តារាងទី ៣ : ក្របខ័ណ្ឌចំណាយថ្នាក់ជាតិឆ្នាំ ២០២៦-២០២៨

| សូចនាករ | 2025ច្ប. | 2026ព្យ. | 2027ព្យ. | 2028ព្យ. |
|---|---|---|---|---|
| **ចំណាយសរុបថ្នាក់ជាតិ** | **17,15%** | **15,79%** | **15,55%** | **15,73%** |
| **វិស័យរដ្ឋបាលទូទៅ** | **1,67%** | **1,53%** | **1,59%** | **1,55%** |
| ចំណាយចរន្ត | 1,57% | 1,43% | 1,49% | 1,44% |
| ចំណាយមូលធន | 0,10% | 0,10% | 0,10% | 0,11% |
| **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **2,73%** | **2,61%** | **2,51%** | **2,42%** |
| ចំណាយចរន្ត | 2,73% | 2,60% | 2,50% | 2,41% |
| ចំណាយមូលធន | 0,01% | 0,01% | 0,01% | 0,01% |
| **វិស័យសង្គមកិច្ច** | **5,14%** | **4,95%** | **4,96%** | **4,89%** |
| ចំណាយចរន្ត | 4,57% | 4,41% | 4,43% | 4,26% |
| ចំណាយមូលធន | 0,57% | 0,55% | 0,54% | 0,64% |
| **វិស័យសេដ្ឋកិច្ច** | **3,88%** | **3,71%** | **3,53%** | **3,79%** |
| ចំណាយចរន្ត | 0,89% | 0,85% | 0,79% | 0,76% |
| ចំណាយមូលធន | 2,99% | 2,85% | 2,74% | 3,03% |
| **ចំណាយផ្សេងៗ** | **3,72%** | **2,99%** | **2,96%** | **3,07%** |
| ចំណាយចរន្ត | 1,82% | 1,89% | 1,82% | 1,79% |
| ចំណាយមូលធន | 1,89% | 1,10% | 1,15% | 1,28% |

ផ្អែកលើ**ក្របខ័ណ្ឌចំណាយតាមវិស័យរយៈពេលមធ្យមដែលបានកំណត់ខាងលើនេះ, រាជរដ្ឋាភិបាលមានលទ្ធភាព**បង្កើនចំណាយមិនមែនបន្ទុកបុគ្គលិកតាមវិស័យសម្រាប់ឆ្នាំ ២០២៦ បានត្រឹម ៤% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៥, ដោយផ្តល់អាទិភាពសម្រាប់ដោះស្រាយតម្រូវការចំណាយចាំបាច់មិនអាចខានបាន ឬមិនអាចពន្យារពេលបាន និងចំណាយតាមគោលការណ៍កំណត់ច្បាស់លាស់។ ក្នុងន័យនេះ, ស្ថិតក្នុងបរិការណ៍នៃភាពមិនច្បាស់លាស់ពីផលប៉ះពាល់នៃបញ្ហាការអនុវត្តអត្រាពន្ធគយបដិការរបស់សហរដ្ឋអាមេរិក, ការកំណត់ពិតានចំណាយគោលសម្រាប់ក្រសួង ស្ថាប័នផ្នែកចំណាយមិនមែនបន្ទុកបុគ្គលិក ជាទូទៅត្រូវបានផ្តល់ទាបជាងច្បាប់ថវិកាឆ្នាំ ២០២៥ ឬ យ៉ាងច្រើនត្រូវបានរក្សាកញ្ចប់ស្មើនឹងច្បាប់ថវិកាឆ្នាំ ២០២៥ អាស្រ័យលើកត្តាជាក់ស្តែងនៃក្រសួង ស្ថាប័ន។ ជារួមគឺ ក្រសួង ស្ថាប័ន ត្រូវបានដកចេញនូវសកម្មភាពដែលត្រូវបញ្ចប់ក្នុងឆ្នាំ ២០២៥ ឬ កាត់បន្ថយមុខចំណាយមិនប្រចាំ ព្រមទាំងធ្វើវិចារណកម្មចំណាយមួយចំនួន ជាពិសេសចំណាយដែលអាចសន្សំសំចៃបាន ទាំងលើទិដ្ឋភាពប្រសិទ្ធភាពបច្ចេកទេស ទាំងលើទិដ្ឋភាពតម្លៃនៃលុយ។ សារៈសំខាន់នៃការកាត់បន្ថយនេះ គឺដើម្បីរក្សាលទ្ធភាពកម្រិតធនធានដែលមានក្នុងឆ្នាំ ២០២៥ ជាលំហថវិកាសម្រាប់ពិភាក្សានៅដំណាក់កាលចរចារថវិកា ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចមានលទ្ធភាពដោះស្រាយតម្រូវការចំណាយថ្មីៗដែលជាកិច្ចការអាទិភាពរបស់ក្រសួង ស្ថាប័ន និងរបស់រាជរដ្ឋាភិបាល ដូចបានជម្រាបជូនខាងលើ ជាពិសេសសម្រាប់រាជរដ្ឋាភិបាលមានលទ្ធភាពត្រៀមលក្ខណៈឱ្យបានសមស្រប តាមដែលអាចធ្វើទៅបានក្នុងការធ្វើអន្តរាគមន៍ដោះស្រាយសំពាធចំណាយថ្មីៗ ដែលអាចកើតឡើងជាយថាហេតុពាក់ព័ន្ធនឹងការរក្សាលំនឹងជីវភាពប្រជាជន

និងលំនឹងសេដ្ឋកិច្ច ហើយកាន់តែសំខាន់ទៅទៀតនោះ គឺត្រៀមលក្ខណៈសម្រាប់សេណារីយ៉ូទាបជាយថាហេតុ ដូចមានការវិភាគនៅក្នុងផ្នែកហានិភ័យហិរញ្ញវត្ថុសាធារណៈ នៃឯកសារក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ២០២៦-២០២៨។

ស្របតាមវិធីសាស្ត្រ និងអភិក្រម ដូចបានជម្រាបជូននេះ, **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** បានកំណត់**ពិតានចំណាយគោលផ្នែកចំណាយចរន្ត** សម្រាប់គ្រប់ក្រសួង ស្ថាប័ន, ចំណែកឯ, **ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ** ត្រូវបានកំណត់សម្រាប់ក្រសួង ស្ថាប័ន ចំនួន ១១ និង**ពិតានចំណាយគោលផ្នែកចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានកំណត់សម្រាប់ក្រសួង ស្ថាប័ន ចំនួន ១០។

ក្នុងន័យនេះ, **ពិតានចំណាយគោលកម្រិតក្រសួង ស្ថាប័នឆ្នាំ ២០២៦-២០២៨ ត្រូវបានរៀបចំ និងបានវិភាជជូនក្រសួង ស្ថាប័ន** ជាកញ្ចប់ពិតានថវិការយៈពេល ៣ ឆ្នាំ ***ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ*** ដើម្បីគោរពសុំការសម្រេចជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង** ត្រូវដាក់អនុវត្តតាមរយៈ **សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦** ដែលនឹងត្រូវដាក់ចេញដោយរាជរដ្ឋាភិបាល នៅក្នុងខែឧសភានេះ។

### ២.២.២. ក្របខ័ណ្ឌចំណាយថ្នាក់ក្រោមជាតិ

**ចំណាយសរុបថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ ២០២៦ ត្រូវបានគ្រោងក្នុងទំហំ ១,៨០% នៃ ផ.ស.ស. ដែលរួមបញ្ចូលការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងទំហំ ០,៧៧% នៃ ផ.ស.ស.។** សម្រាប់ឆ្នាំ ២០២៧-២០២៨, ចំណាយសរុបថ្នាក់ក្រោមជាតិ នឹងគ្រោងឱ្យមានកំណើនក្នុងអត្រាជាមធ្យមប្រមាណ ៦,៤% ក្នុងមួយឆ្នាំ ដែលនឹងស្ថិតក្នុងរង្វង់ ១,៧៥% នៃ ផ.ស.ស. ត្រឹមឆ្នាំ ២០២៨ ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងការលើកកម្ពស់គុណភាពនៃសេវាសាធារណៈនៅមូលដ្ឋាន ព្រមទាំងការផ្តល់ប្រាក់ឧបត្ថម្ភលំហែមាតុភាពដល់សមាជិកក្រុមប្រឹក្សាជាស្ត្រី សម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ ថ្នាក់ និងការបន្តពង្រឹងសមត្ថភាពផ្នែករដ្ឋបាល, បច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការផ្ទេរសិទ្ធិអំណាច, ការទទួលខុសត្រូវមុខងារ និងធនធានពីថ្នាក់ជាតិ តាមរយៈការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី ២ ឆ្នាំ ២០២១-២០៣០។

ផ្អែកលើក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនេះ, ដូចនឹងថវិកាថ្នាក់ជាតិដែរ, **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** របស់រដ្ឋបាលរាជធានី ខេត្ត នឹងត្រូវបានរៀបចំដោយឡែក ដើម្បីផ្តល់ជាពិតានចំណាយគោលជូនដល់រដ្ឋបាលរាជធានី ខេត្តនីមួយៗ សម្រាប់ជាមូលដ្ឋាននៃការផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឆ្នាំ ២០២៦-២០២៨ និង ការរៀបចំគម្រោងថវិកាឆ្នាំ ២០២៦ របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលនឹងត្រូវអនុវត្តតាមរយៈ **សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការាជធានី ខេត្ត ឆ្នាំ ២០២៦-២០២៨ និង នីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២៦** ដែលនឹងត្រូវដាក់ចេញដោយ **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** នៅក្នុងខែឧសភា នេះដែរ ស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣។

## ៣. សេចក្តីសន្និដ្ឋាន

**ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** ត្រូវបានគិតគូរ និងរៀបចំឡើងយ៉ាងហ្មត់ចត់ ដោយផ្អែកលើគោលបំណងចម្បង ដែលត្រូវបានកំណត់ក្នុង **ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ឆ្នាំ ២០២៦-២០២៨** ពោលគឺ ***«ដើម្បីរក្សាលំនឹងជីវភាពប្រជាជន និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការពង្រឹងប្រសិទ្ធភាព និងធានាចីរភាពហិរញ្ញវត្ថុសាធារណៈ សំដៅលើកកម្ពស់សមធម៌សង្គម ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងជំរុញការអភិវឌ្ឍឆ្ពោះទៅចក្ខុវិស័យកម្ពុជា ២០៥០»*** ។ យ៉ាងណាមិញ, **ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៦-២០២៨** ពិតជាបានផ្តល់ជាទស្សនវិស័យអំពីនិន្នាការចំណូល និងចំណាយថវិកាជាតិ ក៏ដូចជាលំហថវិកា ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចមានលទ្ធភាពដោះស្រាយបាននូវតម្រូវការចំណាយជាយុទ្ធសាស្ត្រ និងជាអាទិភាព សម្រាប់រយៈពេលខ្លី និងមធ្យម ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាខ្លាំងពីកត្តាខាងក្រៅ ជាពិសេសដោយសារការដាក់ចេញនូវវិធានការគោលនយោបាយពន្ធគយបដិការរបស់សហរដ្ឋអាម៉េរិក។ សំខាន់ជាងនេះទៀត, ការផ្តល់ **ពិតានចំណាយគោលសម្រាប់គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) និងពិតានចំណាយគោលសម្រាប់ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល** បានផ្តល់ជាព័ត៌មានដល់គ្រប់ក្រសួង ស្ថាប័ន អំពីភាពអាចប៉ាន់ប្រមាណបាននៃធនធានថវិកាដែលអាចទទួលបាន, ក្នុងបរិការណ៍បច្ចុប្បន្នដែលប្រកបដោយហានិភ័យខ្ពស់នេះ, សម្រាប់ការរៀបចំ **ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៦-២០២៨** និងការរៀបចំ **គម្រោងថវិកាឆ្នាំ ២០២៦** ព្រមទាំងផ្តល់លទ្ធភាពដល់គ្រប់ក្រសួង ស្ថាប័ន អាចធ្វើអាទិភាវូបនីយកម្មមុខចំណាយ និងធ្វើវិចារណកម្មចំណាយជាមួយនឹងធនធានដែលមាន ដើម្បីធានាជោគជ័យ ក្នុងការអនុវត្តគោលនយោបាយគន្លឹះនានារបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងបន្តតាមដាន ដោយយកចិត្តទុកដាក់លើការវិវត្ត និងវាយតម្លៃសភាពការណ៍ឡើងវិញ មុនពេលរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៦ ដើម្បីកែសម្រួលក្របខ័ណ្ឌនេះតាមការចាំបាច់ និងតាមការណ៍ជាក់ស្តែង ជាពិសេសក្នុងកាលៈទេសៈដែលសភាពការណ៍មិនអំណោយផល។

# ឧបសម្ព័ន្ធ
# ស្ដីពី
# ពិតានចំណាយគោលឆ្នាំ ២០២៦-២០២៨ សម្រាប់ក្រសួង ស្ថាប័ន និង សម្រាប់ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈរដ្ឋបាល

## ពិតានចំណាយគោលឆ្នាំ ២០២៦-២០២៨ សម្រាប់ក្រសួង ស្ថាប័ន

ឯកតា : លានរៀល

| ក្រសួង ស្ថាប័ន | គម្រោងថវិកាឆ្នាំ ២០២៦ | គម្រោងថវិកាឆ្នាំ ២០២៧ | គម្រោងថវិកាឆ្នាំ ២០២៨ |
|---|---|---|---|
| **ក. វិស័យរដ្ឋបាលទូទៅ** | | | |
| **០១. ព្រះបរមរាជវាំង** | 88.617 | 90.413 | 92.232 |
| **សរុបចំណាយចរន្ត** | **88.617** | **90.413** | **92.232** |
| - បន្ទុកបុគ្គលិក * | 41.256 | 41.702 | 42.104 |
| - មិនមែនបន្ទុកបុគ្គលិក | 47.361 | 48.711 | 50.129 |
| **០២. រដ្ឋសភា** | 186.683 | 191.984 | 197.229 |
| **សរុបចំណាយចរន្ត** | **186.683** | **191.984** | **197.229** |
| - បន្ទុកបុគ្គលិក * | 114.046 | 116.178 | 118.096 |
| - មិនមែនបន្ទុកបុគ្គលិក | 72.637 | 75.806 | 79.133 |
| **០៣. ព្រឹទ្ធសភា** | 98.739 | 101.131 | 103.475 |
| **សរុបចំណាយចរន្ត** | **98.739** | **101.131** | **103.475** |
| - បន្ទុកបុគ្គលិក * | 62.953 | 64.064 | 65.063 |
| - មិនមែនបន្ទុកបុគ្គលិក | 35.786 | 37.067 | 38.412 |
| **០៤. ក្រុមប្រឹក្សាធម្មនុញ្ញ** | 14.997 | 15.276 | 15.547 |
| **សរុបចំណាយចរន្ត** | **14.997** | **15.276** | **15.547** |
| - បន្ទុកបុគ្គលិក * | 12.340 | 12.493 | 12.631 |
| - មិនមែនបន្ទុកបុគ្គលិក | 2.657 | 2.783 | 2.916 |
| **០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី** | 564.566 | 571.369 | 578.114 |
| **សរុបចំណាយចរន្ត** | **564.566** | **571.369** | **578.114** |
| - បន្ទុកបុគ្គលិក * | 85.281 | 87.926 | 90.305 |
| - មិនមែនបន្ទុកបុគ្គលិក | 479.285 | 483.443 | 487.809 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 11.111 | 11.444 | 11.788 |

| ក្រសួង ស្ថាប័ន | គម្រោងថវិកាឆ្នាំ ២០២៦ | គម្រោងថវិកាឆ្នាំ ២០២៧ | គម្រោងថវិកាឆ្នាំ ២០២៨ |
|---|---|---|---|
| **០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | **12.270** | **12.985** | **13.743** |
| **សរុបចំណាយចរន្ត** | **12.250** | **12.965** | **13.723** |
| - បន្ទុកបុគ្គលិក * | 2.241 | 2.280 | 2.314 |
| - មិនមែនបន្ទុកបុគ្គលិក | 10.009 | 10.685 | 11.409 |
| **សរុបចំណាយមូលធន** | **20** | **20** | **20** |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 20 | 20 | 20 |
| + គម្រោងវិនិយោគផ្ទាល់ | 20 | 20 | 20 |
| • ទ្រព្យសកម្មរយៈពេលវែង | 20 | 20 | 20 |
| **០៨. ក្រសួងអធិការកិច្ច** | **48.826** | **51.189** | **53.490** |
| **១. ក្រសួង** | **26.878** | **28.114** | **29.307** |
| **សរុបចំណាយចរន្ត** | **26.878** | **28.114** | **29.307** |
| - បន្ទុកបុគ្គលិក * | 16.254 | 16.960 | 17.596 |
| - មិនមែនបន្ទុកបុគ្គលិក | 10.624 | 11.154 | 11.711 |
| **៩. មន្ទីរជំនាញ** | **21.948** | **23.075** | **24.183** |
| **សរុបចំណាយចរន្ត** | **21.948** | **23.075** | **24.183** |
| - បន្ទុកបុគ្គលិក * | 9.273 | 9.767 | 10.211 |
| - មិនមែនបន្ទុកបុគ្គលិក | 12.675 | 13.308 | 13.972 |
| **០៩. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** | **186.936** | **195.377** | **203.834** |
| **សរុបចំណាយចរន្ត** | **186.936** | **195.377** | **203.834** |
| - បន្ទុកបុគ្គលិក * | 64.224 | 66.924 | 69.353 |
| - មិនមែនបន្ទុកបុគ្គលិក | 122.712 | 128.453 | 134.481 |
| **១០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **1.146.729** | **1.293.836** | **1.435.024** |
| **១. ក្រសួង** | **1.114.012** | **1.259.406** | **1.398.912** |
| **សរុបចំណាយចរន្ត** | **1.107.882** | **1.237.262** | **1.371.165** |
| - បន្ទុកបុគ្គលិក * | 188.304 | 198.151 | 207.012 |
| - មិនមែនបន្ទុកបុគ្គលិក<br>ក្នុងនោះ ៖ | 919.578 | 1.039.112 | 1.164.153 |

| ក្រសួង ស្ថាប័ន | គម្រោងថវិកា ឆ្នាំ ២០២៦ | គម្រោងថវិកា ឆ្នាំ ២០២៧ | គម្រោងថវិកា ឆ្នាំ ២០២៨ |
|---|---|---|---|
| + គ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.925 | 9.193 | 9.469 |
| + ជំពូក ៦៦ : បន្ទុកហិរញ្ញវត្ថុ | 721.830 | 833.091 | 949.445 |
| **សរុបចំណាយមូលធន** | **6.130** | **22.143** | **27.747** |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 6.130 | 22.143 | 27.747 |
| + គម្រោងវិនិយោគផ្ទាល់ | 6.130 | 22.143 | 27.747 |
| • គម្រោងវិនិយោគសាធារណៈ | 6.100 | 22.113 | 27.717 |
| • ទ្រព្យសកម្មរយៈពេលវែង | 30 | 30 | 30 |
| **៩. មន្ទីរជំនាញ** | **32.718** | **34.431** | **36.111** |
| **សរុបចំណាយចរន្ត** | **32.368** | **34.081** | **35.761** |
| - បន្ទុកបុគ្គលិក * | 13.831 | 14.618 | 15.326 |
| - មិនមែនបន្ទុកបុគ្គលិក | 18.537 | 19.463 | 20.435 |
| **សរុបចំណាយមូលធន** | **350** | **350** | **350** |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 350 | 350 | 350 |
| + គម្រោងវិនិយោគផ្ទាល់ | 350 | 350 | 350 |
| • ទ្រព្យសកម្មរយៈពេលវែង | 350 | 350 | 350 |
| **១៤. ក្រសួងផែនការ** | **89.932** | **94.353** | **98.498** |
| **១. ក្រសួង** | **48.017** | **50.065** | **51.974** |
| **សរុបចំណាយចរន្ត** | **48.017** | **50.065** | **51.974** |
